JICA Cambodia Office - JICA カンボジア事務所

July 25 ·

[ការបណ្តុះបណ្តាលគ្រូបង្គោលវគ្គ៣(ToT3)នៃការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ(INSET) សម្រាប់គិលានុបដ្ឋាកបានបញ្ចប់ដោយជោគជ័យនៅក្នុងខេត្តសាកល្បង(JICA Strings Project)/ Third Round of Training of Trainers for In-Service Training (INSET) for Nurses Successfully Completed in Pilot Provinces - JICA Strings Project]

---------------------------------------

ចាប់ពីខែធ្នូ ឆ្នាំ២០២៤ ដល់ខែឧសភា ឆ្នាំ២០២៥ គម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (Strings Project) សហការជាមួយនឹងនាយកដ្ឋានអភិវឌ្ឍធនធានមនុស្ស (HRDD) នៃក្រសួងសុខាភិបាល (MoH) និងដោយមានការចូលរួមពីគ្រូបង្គោលវគ្គ១ និងវគ្គ២ បានធ្វើការបណ្តុះបណ្តាលម៉ូឌុលទាំង៨ សម្រាប់គ្រូបង្គោលវគ្គ៣ (ToT3) ដើម្បីក្លាយជាគ្រូវគ្គបណ្តុះបណ្តាល INSET នាពេលអនាគតនៅខេត្តបាត់ដំបង និងខេត្តកំពង់ចាម ។

បន្ទាប់ពីវគ្គToT3 បានបញ្ចប់ គម្រោងក៏បានរៀបចំវគ្គសម្រាប់ការបង្រៀនសាកល្បង(Demo)នៅខេត្ត បាត់ដំបង និងកំពង់ចាម ដើម្បីឱ្យគ្រូបង្គោលផ្តល់មតិត្រឡប់ទៅគ្រូបណ្តុះបណ្តាល INSET ថ្នាក់ខេត្តបានបង្កើនជំនាញក្នុងការបង្រៀនបន្ថែមទៀត។

ជាលទ្ធផល នៅខេត្តបាត់ដំបងមានសិក្ខាកាមវគ្គToT3 សរុបចំនួន១០០នាក់ និង៧៧នាក់ នៅខេត្ត កំពង់ចាម បានបំពេញតាមលក្ខខណ្ឌរបស់វគ្គបណ្តុះបណ្តាល ដោយផ្អែកលើអត្រា នៃការចូលរួម និង លទ្ធផលតេស្តក្រោយវគ្គបណ្តុះបណ្តាល ដែលទទួលស្គាល់ពីក្រសួងសុខាភិបាល និងត្រូវបានទទួលស្គាល់ជាគ្រូបង្គោលសម្រាប់ INSET ។ គ្រូបណ្តុះបណ្តាល គឺដើរតួនាទីយ៉ាងសំខាន់សម្រាប់វគ្គ INSET នាពេលអនាគតហើយបច្ចុប្បន្ននេះខេត្តសាកល្បងទាំងពីរ កំពុងចាប់ផ្តើមរៀបចំធ្វើផែនការបណ្តុះបណ្តាល។

គម្រោងនេះនឹងបន្ត ធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូពាក់ព័ន្ធសំខាន់ៗ ជាពិសេសនាយកដ្ឋានអភិវឌ្ឍធនធានមនុស្ស ក្រុមការងារគ្រប់គ្រងការ បណ្តុះបណ្តាលថ្នាក់ជាតិ និងថ្នាក់ខេត្ត មន្ទីរសុខាភិបាលនៃ រដ្ឋបាលខេត្ត សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ មន្ទីរពេទ្យបង្អែកខេត្ត និងគ្រូបង្គោល ដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលក្នុងពេលបម្រើការងារប្រកបដោយប្រសិទ្ធភាព៕

គេហទំព័រគម្រោង:

The Project for Strengthening In-service Training System in Cambodia

https://www.jica.go.jp/oda/project/2004000/index.html...

From December 2024 to May 2025, JICA Project for Strengthening In-Service Training for Health Human Resources (Strings Project) together with the Human Resource Development Department (HRDD) of the Ministry of Health (MoH) conducted a series of the Third round of Training of Trainers (ToT3) for future INSET trainers in the pilot provinces of Battambang (BTB) and Kampong Cham (KC).

Senior trainers— Core trainers and Trainers who had been developed through ToT1 and ToT2 — delivered lectures on eight essential modules to the future provincial INSET trainers. Following the ToT3 sessions, demonstration sessions were conducted in both BTB and KC to provide constructive feedback from senior trainers to further enhance new trainer´s teaching skills.

As a result, a total of 100 participants in BTB and 77 in KC, who fulfilled the qualification criteria based on attendance rates and post-training examination results, were certified by the MoH and formally designated as INSET trainers. These trainers will play a leading role in the upcoming INSET sessions currently under planning in each respective province.

The Project will continue to work closely with key stakeholders—particularly HRDD, the National and Provincial Training Management Teams, PHDs, RTCs, PRHs, and certified INSET trainers to support the effective implementation of the INSET program.

Project Website:

The Project for Strengthening In-service Training System in Cambodia

https://www.jica.go.jp/oda/project/2004000/index.html...









